គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee
for Cambodia

Comité de Coopération
Pour le Cambodge

**ទស្សនវិស័យ:** ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងប្រជាធិបតេយ្យសម្រាប់ប្រទេសកម្ពុជា
**Vision:** Sustainable and democratic development for Cambodia

# កំណត់ហេតុ

## វេទិការៀនសូត្រហិរញ្ញវត្ថុលើកទី២៩
## អនុលោមភាពកាតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

**ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០២២**



## ១. សេចក្តីផ្តើម

គណៈកម្មធិការសហប្រតិបត្តិការដើម្បីកម្ពុជា ជាអង្គការសមាជិកភាពដ៏ធំ និងមានវ័យចំណាស់ជាងគេ (គសក) មួយនៅក្នុងប្រទេសកម្ពុជា។ រហូតមកដល់ខែកុម្ភៈ ឆ្នាំ ២០២២ អង្គការ គសក មានសមាជិកជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសចំនួនជិត២០០ស្ថាប័ន។ បច្ចុប្បន្ននេះ អង្គការ គសក បាននឹងកំពុងអនុវត្តកម្មវិធីអភិបាលកិច្ចដំណាក់កាលទី៤ឆ្នាំ ២០២១ ដល់ ២០២៣។ កម្មវិធីនេះមានគោលបំណងសំខានចំនួន២៖ ទី១ គឺធ្វើអោយប្រសើរឡើងនូវបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិលនិងទី២ គឺ មជ្ឈមណ្ឌលធនធានប្រកបដោយនិរន្តរភាពសម្រាប់អង្គការសង្គមស៊ីវិលទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ។

ក្របខ័ណ្ឌគតិយុត្តិស្តីពីគណនេយ្យ និងសវនកម្ម និងនិន្នាការបច្ចុប្បន្នភាពនៃការរាតត្បាតនៃជំងឺកូវីដ ១៩ ស្តីពីការធ្វើអនុលោមភាពតាមច្បាប់ ទាក់ទងនឹងប្រតិបត្តិការរបស់ អង្គការសង្គមស៊ីវិលបាន បង្ហាញការវិវត្តគួរឱ្យចាប់អារម្មណ៍ ជាពិសេសលើសមត្ថភាពអនុលោមភាព និងផលជះលើបរិយាកាសអំណោយផលនៅក្នុងប្រទេសកម្ពុជា ។ និយ័តករគណនេយ្យ និងសវនកម្ម (ន.គ.ស) បំពេញមុខងារជាសេនាធិការឱ្យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រង និងអភិវឌ្ឍវិស័យ និងវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៅកម្ពុជា តាមរយៈការដាក់ចេញនូវបទប្បញ្ញត្តិ វិធាន និងស្តង់ដា ដោយជំរុញការអនុវត្តច្បាប់ និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ ។ កាលពីថ្ងៃទី១៥ មីនា ឆ្នាំ២០២២ និយ័តករគណនេយ្យ និងសវនកម្មបានចេញសេចក្តីណែនាំស្តីពី ការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្ម សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ។ ដើម្បីបង្កើនការយល់ដឹងពីការអនុវត្តកាតព្វកច្ចិគណនេយ្យ និងសវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងចូលរួមផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនានា។

អង្គការ គ ក នឹងរៀបចំវេទិការៀនសូត្រស្តីពី.ស.***អនុលោមភាពកាតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ*** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ សុក្រ ទី ៨ ខែ មេសា ឆ្នាំ២០២២ ចាប់ពីម៉ោង ៨.៣០ រសៀលដល់ម៉ោង ៤.៣០ រសៀល នៅមជ្ឈមណ្ឌលដាយកូនៀ។

## ២. ដំណើរការ និងលទ្ធផល

- ចែករំលែកខ្លឹមសារ និងពន្យល់បន្ថែមលើសេចក្តីណែនាំស្តីពីការអនុវត្តកាតូកិច្ចគណនេយ្យ និងសវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ។
- រៀន និងអនុវត្តទម្រង់របាយការណ៍ហិរញ្ញវត្ថុដែលចេញដោយនិយ័តករគណនេយ្យ និងសវនកម្ម។
- ពង្រីកទំនាក់ទំនងបណ្តាញសង្គម និងតាមប្រព័ន្ធអនឡាញសម្រាប់អ្នកគ្រប់គ្រងធនធានមនុស្ស។

## អ្នកចូលរួមក្នុងវេទិការៀនសូត្រ

វេទិការៀនសូត្រនេះត្រូវបានធ្វើជាទម្រង់កូនកាត់ដែលមានទាំងការជួបដោយផ្ទាល់ និងតាមប្រព័ន្ធសិក្សាពីចម្ងាយ (ZOOM) ដែលមានអ្នកចូលរួមដោយផ្ទាល់សរុបចំនួន៥១នាក់ ស្រី៣២នាក់ និងអ្នកចូលរួមតាមប្រព័ន្ធ Zoom សរុបចំនួន១៧៥នាក់។

- សមាសភាពចូលរួមមាន៖
- និយ័តករគណនេយ្យ និងសវនកម្ម
- ក្រុមហ៊ុន Reach & Partners
- ក្រុមការងារបច្ចេកទេស ហិរញ្ញវត្ថុ និងពន្ធដារ
- អង្គការសមាជិក និងមិនមែនសមាជិករបស់ គសក

## ២.១ មតិស្វាគមន៍ និងបើកកម្មវិធី

**លោកស្រី ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិនៃអង្គការ CCC បានមានមតិស្វាគមន៍ដល់សិក្ខាកាមនៃវេទិការៀនសូត្រ។

- សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់និយ័តករដែលតែងតែគាំទ្រ និងផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អជាមួយអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាតាំងពីដើមរហូតមក។
- វេទិការៀនសូត្រត្រូវបានរៀបចំឡើងជាច្រើនដងតាំងពីខែ សីហា ២០១៨ មក



- តាមរយៈវេទិកានេះដែរយើងបានរៀនសូត្រនូវប្រធានបទសំខាន់ៗមួយចំនួនដូចជាច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពសមាគមន៍មិនស្វែងរក
- ថ្វីត្បិតតែយើងជាអង្គការសង្គមស៊ីវិលមែនតែយើងបានចូលរួមចំណែកក្នុងការផ្សព្វផ្សាយពីច្បាប់នានាដែលមានការពាក់ព័ន្ធក្នុងគោលបំណងដើម្បីពង្រឹងភាពជាដៃគូជាមួយរាជរដ្ឋាភិបាល ដើម្បីធានានូវតម្លាភាព និងប្រសិទ្ធភាពនៃការអនុវត្តការងារ។
- កន្លងមកយើងបានប្រមូលធាតុចូល និងអនុសាសន៍ជាច្រើនស្តីពីអនុលោមភាពនៃសេចក្តីព្រៀងស្តីស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ
- សូមថ្លែងអំណរគុណនូវការបន្តចូលរួម និងសាមគ្គីភាពក្នុងការធ្វើការជាដៃគូ
- កន្លងមកខាងនិយ័តករបានប្រមូលធាតុចូល និងការកែសម្រួល និងប្រើប្រាស់វាក្យស័ព្ទមួយចំនួនផងដែរ

- សំណូមពររបស់របស់អង្គការសង្គមស៊ីវិលរបស់យើងក៏ត្រូវបានយកទៅពិចារណា
- សូមគោរពជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានមានវត្តមានក្នុងវេទិការបស់យើងពេលនេះ សូមជួបតែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ សុខសប្បាយជៀសឆ្ងាយពីកូវីដទាំងអស់គ្នា!

## បើកកម្មវិធី ដោយ **លោក សេខ តុលា** អគ្គនាយករងនៃនិយ័តករគណនេយ្យ និងសវនកម្ម (ស.គ.ន)

(តាមប្រព័ន្ធ Zoom )

- ជាបឋមសូមគោរពលោកស្រី ស៊ិន ពុទ្ធារី នាយិកាប្រតិបត្តិ គសក
- សូមស្វាគមន៍អ្នកចូលរួមទាំងអស់គ្នាទាំងអ្នកចូលរួមផ្ទាល់ និងពីចម្ងាយ
- ប្រធានបទសម្រាប់វេទិការៀនសូត្រថ្ងៃនេះគឺ អនុលោមភាពកាតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ



- យើងពិតជាបានមានកិច្ចសហការគ្នាល្អតាំងពីឆ្នាំ ២០១៨ មកម្លេះតាំងពីនៅឈ្មោះចាស់ជាក្រុមប្រឹក្សាជាតិគណនេយ្យ ដែលបច្ចុប្បន្នត្រូវបានប្តូរឈ្មោះមកជា និយ័តករគណនេយ្យ និងសវនកម្ម
- ថ្មីៗនេះរាជរដ្ឋាភិបាលបានប្រកាសអោយស្ថាប័នអង្គការសមាគមមិនស្វែងរកប្រាក់ចំណេញចាប់ផ្តើមអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មស្របតាមសេចក្តីណែនាំលេខ០១០ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០២២
- ក្នុងសេចក្តីណែនាំនោះបានបង្ហាញកាតួកិច្ចសំខាន់សម្រាប់អង្គការ សមាគមន៍
- យើងសហការយ៉ាងជិតស្និទជាមួយ គសក ក្នុងការផ្សព្វផ្សាយពីស្តង់ដារគណនេយ្យ សម្រាប់អង្គការសមាគមន៍ មិនស្វែងរកប្រាក់ចំណេញ
- ប្រធានបទទី១នឹងត្រូវបានធ្វើបទបង្ហាញដោយ និយ័តករ គណនេយ្យ និងសវនកម្ម
- ប្រធានបទទី២ នឹងមានបទបង្ហាញពីវិស័យឯកជន លើការបង្ហាញពីទម្រង់របាយការណ៍ហិរញ្ញវត្ថុ
- ការអនុវត្តកតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់អង្គការមិនស្វែងរកប្រាក់ចំណេញគឺជារឿងចាំបាច់ដែលយើងត្រូវតែធ្វើអោយបាន
- អរគុណ ដល់លោកស្រី ស៊ិន ពុទ្ធារី និងសហការី គសក ដែលតែងមានកិច្ចសហប្រតិបត្តិការយ៉ាងល្អជាមួយនិយ័តករ គណនេយ្យ និងសវនកម្មរហូតមក
- ជាទីបញ្ចប់សូមជូនពរ លោកស្រី ស៊ិន ពទ្ធារី និង សហការី ជួបតែពុទ្ធពរទាំង៤ប្រការ និងជៀសឆ្ងាយពីកូវីដ និងនៅតែចូលរួមអនុវត្តវិធានការ ៣ កុំ និង ៣ការពារ។
- សូមប្រកាសបើកអង្គវេទិការៀនសូត្ររបស់យើងចាប់ពីពេលនេះតទៅ!!!

# ប្រធានបទទី៦៖ ការធ្វើបទបង្ហាញ និងការពន្យល់បន្ថែមលើសេចក្ដីណែនាំស្ដីពី ការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញដោយ លោក សឿន បូតេ អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាពនៃនិយ័តករគណនេយ្យ និងសវនកម្ម (ស.គ.ន)

## <u>មាតិកា</u>

1. កាន់បញ្ជីគណនេយ្យ និងហិរញ្ញវត្ថុ
2. ដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
3. ស្នើសុំផ្លាស់ប្ដូរកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ
4. ប្រើភាសានៅក្នុងប្រព័ន្ធគណនេយ្យកំព្យូទ័រ ឬប្រព័ន្ធកំព្យូទ័រពាក់ព័ន្ធ
5. ការប្រើប្រាស់ប្រព័ន្ធ E-Filing System)
6. ពិន័យអន្តរការណ៍ និងការចុះត្រួតពិនិត្យ

ចំពោះសេចក្ដីលំអិតនៃបទបង្ហាញសូមពិនិត្យមើលឯកសារដែលបានភ្ជាប់ជូនខាងក្រោម៖

PDF
ការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មស

## សំណួរ និងចម្លើយ

| សំណួរ | ចម្លើយ |
|---|---|
| តើយើងត្រូវមានលក្ខណ្ឌអ្វីខ្លះទើបអាចដឹងថាអង្គការរបស់យើងត្រូវរងសវនកម្មឯករាជ្យមកពីអុកហ្វាម ? | • សូមទៅពិនិត្យមើលប្រកាសលេខ៥៦៣ ស្ដីពីកាតព្វកិច្ចដាក់របាយការហិរញ្ញវត្ថុ<br>• មានទំហំចរិកាចំណាយចាប់ពី ៥០ ម៉ឺនដុល្លារ<br>• ចំនួនបុគ្គលិកចាប់ពី២០នាក់ឡើងទៅ។ |
| លោក គឹម ហេង មកពីអង្គការសម្ព័ន្ធចាប់ដៃ៖ តើប្រព័ន្ធ E-filing បានដាក់អោយដំណើរការឬនៅ?<br><br>• តើខាងនិយ័តករមានបង្ហាញពីរបៀបនៃការប្រើប្រាស់ប្រព័ន្ធនោះដែរឬទេ ? | ចម្លើយ៖<br><br>• ប្រព័ន្ធកំពុងតែធ្វើបច្ចុប្បន្នភាព<br>• នឹងមានការធ្វើបទបង្ហាញនៅពេលដាក់ដំណើរការ។ ជារួមសូមស្វែងយល់បន្ថែមលើចំណុចទាំង៥ខាងលើ។ |

| | |
|---|---|
| ការដាក់លិខិតជូនដំណឹងពីការ ដោះដូរឬប្រើប្រាស់ប្រភេទរូបិយប័ណ្ណ តើមានការពន្យារពេល ៦០ថ្ងៃដូចការដាក់របាយការណ៍គណនេយ្យដែរទេ? | • លោក កុសល បន្ថែម៖ ជារួម□□□ សុទ្ធតែត្រូវរងសវនកម្មទាំងអស់។ ត្រូវតែផ្ញើរបាយការណ៍ហិរញ្ញវត្ថុមកនិយ័តករ តាមលក្ខណ្ឌ និងពេលវេលាដែលបានកំណត់។ |
| លោកព្រំ ប៊ុនធឿន មកពី (CYK): អង្គការខ្ញុំបានទទួលលិខិតអនុញ្ញាតសុំផ្លាស់ប្តូរការិយបរិច្ឆេទតែនៅជាប់ឈ្មោះចាស់(NAC)តើត្រូវសុំជាថ្មីឬក៏រក្សានៅដដែល? | ចម្លើយ៖ មិនតម្រូវអោយស្នើសុំឡើងវិញទេ។ |
| ស្រី នាថ មកពី ៖ អង្គការខ្ញុំចូលក្នុងលក្ខខណ្ឌ ដែលត្រូវរងសនវនកម្មឯករាជ្យ កន្លងមកមិនមានថវិកាសម្រាប់ជួលសវនកម្មដែលយើងមិនអាចដាក់របាយការណ៍សវនកម្មជូន តើមានត្រូវទទួលរងពិន័យដែរទេ?<br>តើការដាក់របាយការណ៍សវនកម្មនេះនឹងមានសុពលភាពចាប់ពីពេលណា ? | • ត្រូវរងពិន័យជាទឹកប្រាក់ហើយបើមិនអនុវត្តទៀតត្រូវពិន័យគុណ២ដង។<br>• ការអនុវត្តច្បាប់នេះចាប់ពីឆ្នាំ ២០២១ ។ មានទាំងការកាន់បញ្ជី និងរបាយការណ៍ស្តង់ដារ |
| ហេតុអ្វីបានច្បាប់ចេញមករដាក់រដុប ហើយបែរជាបង្ខំអោយអង្គការអនុត្តវិញ?<br><br>ពីលោក ឆដាភា (IDE Cambodia)<br>សូមណូមពរ៖ ថាដាក់អនុវត្តចុះតែកុំដាក់ពិន័យ។ | ចម្លើយ៖ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្មសម្រាប់សហគ្រាស វាមានយូរមកហើយតាំងពីឆ្នាំ ២០០២។ រដ្ឋាភិបាលមិនដែលបានដាក់អោយអនុវត្ត និងមានការដាក់ទោសទណ្ឌនៅឡើយទេ។ តែពេលនេះជាពេលសមស្របក្នុងការអនុវត្ត។<br>មុនពេលដែលប្រព័ន្ធមិនទាន់ដំណើរការល្អ សូមអង្គការសមាគមន៍ទាំងអស់ត្រៀមខ្លួនអោយបានរួចរាល់។<br>និយ័តករអាចគ្រាន់តែកត់សំណើនេះទុកប៉ុណ្ណោះតែមិនអាចធានាថាអត់នោះទេព្រោះច្បាប់នេះត្រូវបានដាក់អោយអនុត្តហើយ។ |

| | |
|---|---|
| ៦ (សំណើសុំ២ ៖ ១ (សុំមានជម្រើសថា អង្គការមិនស្វែងរកប្រាក់ចំណេញ។ ២សុំដាក់របាយការណ៍តែជា ( Soft Copy បានហើយ !ពីលោក<br>ចាន់ សារិទ្ធ | និយ័តករបានគិតគូរពីចំណុចទាំងនេះដែរហើយ តែដោយសារតែប្រព័ន្ធមិនទាន់រួចរាល់ សូមប្រើជាHard copy សិន។ មកពីចូលប្រព័ន្ធខុស ប្រព័ន្ធដែលបានដាក់អោយ) ប្រព័ន្ធ (ប្រើប្រាស់បច្ចុប្បន្នគឺសម្រាប់ក្រុមហ៊ុន សហគ្រាស សម្រាប់អង្គការនៅមិនទាន់រួចរាលនៅឡើយទេ។<br>បន្ថែមដោយលោក សេង តុលា៖<br>• សូមចាប់ផ្តើមរៀបចំរបាយការណ៍ពីពេលនេះ ដោយមិនចាំបាច់រងចាំប្រព័ន្ធរួចរាល់នោះទេ។ លើកទឹកចិត្តអោយពិនិត្យមើលផ្ទៃក្នុងរបស់សមីអង្គការពីលទ្ធភាពក្នុងក្នុងអនុវត្ត។<br>២០២១គឺត្រូវតែដាក់របាយការណ៍តាមពេលកំណត់។ សូមរៀបចំខ្លួន!<br>• អង្គការដែលជាប់លក្ខណ្ឌរងសវនកម្មតែមិនមានថវិកាឬមិនបានបំពេញកាតព្វកិច្ចទាំងនេះ សូមដាក់លិខិតមកនិយ័តករដោយរៀបរាប់ពីបញ្ហារបស់អង្គការខ្លួន ហើយនិយ័តករនឹងពិនិត្យ និងធ្វើការណាត់ជួបពិភាក្សាលំអិតលើករណីដែលបានស្នើនោះ។<br>• សម្រាប់ឆ្នាំ២០២២នេះមានជម្រើសមួយផ្សេងទៀត អង្គការលោកអ្នកក៏អាចធ្វើសវនកម្មរួមទាំង២ឆ្នាំជាមួយគ្នាតែម្តង (២០២១និង២០២២)ក៏បានផងដែរដើម្បីបំពេញកាតួកិច្ចនេះ។ |
| (ដាច់សេវាអ៊ីនធឺណែតពេលលើកសំណួរ) | ចម្លើយ៖ ទាំងអង្គការជាប់សវនកម្ម និងមិនជាប់កាតព្វកិច្ចក៏ត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុមកដែរគ្រាន់តែមិនមានត្រារបស់សវនកម្មឯករាជ្យប៉ុណ្ណោះ។<br>- ចំពោះការប្រើភាសា ត្រូវជូនដំណឹងតាមប្រព័ន្ធអនឡាញ តាមគម្រូដែលផ្ញើជូន។ |

| | |
|---|---|
| | - របាយការណ៍ដែលបានធ្វើសវនកម្មហើយគឺយករបាយការណ៍នេះតែម្តងដើម្បីដាក់ជូនមកនិយ័តករ។ |
| ខ្ញុំមានការបារម្ភណ៍នៅពេលដែលមានរបាយការណ៍ច្រើនដែលតម្រូវគឺធ្វើអោយមានការលំបាកសម្រាប់អង្គការណាស់ក្នុងការរៀបចំនិងដាក់អោយបានទាន់ពេល។ ដោយលោក ឆដាភា | - របាយការណ៍ដែលបានធ្វើសវនកម្មឯករាជ្យលោកអ្នកអាចយករបាយការណ៍នោះដាក់មកនិយ័តករបានតែម្តងមិនចាំធ្វើរបាយការណ៍ណាផ្សេងទៀតនោះទេ។<br>- របាយការណ៍របស់ក្រសួង និងស្ថាប័នដ៏ទៃ( ដូចជាក្រសួងសេដ្ឋកិច្ច ពន្ធដារ និងមហាផ្ទៃ ) គឺយើងបានជជែកគ្នារួចហើយ គឺទម្រង់ដូចគ្នា។ |
| 10) តើរបាយការណ៍ប្រចាំឆ្នាំត្រូវតម្រូវអោយដាក់ដែរទេ ? | មិនតម្រូវអោយដាក់របាយការណ៍ប្រចាំឆ្នាំណាផ្សេងទៀតទេក្រៅពីរបាយការន៍រងសវនកម្ម ឬរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនោះទេ។ |

## ប្រធានបទទី២៖ ការបទបង្ហាញនូវអំពីទម្រង់របាយការណ៍ដាក់ជូននិយ័តករណ៍ដាក់ជូននិយ័តករគណនេយ្យ និងសវនកម្ម ដោយលោក ឿន ប៊ុន ហេង តំណាងពីក្រុមហ៊ុន Reach &Partner

ការបង្ហាញរបៀបចូលទៅកាន់ទម្រង់របាយការណ៍ និងរបៀបនៃការបំពេញ

( សូមពិនិត្យមើលទម្រង់ភ្ជាប់ជូន )

20190102201246_គំរូរបាយការណ៍សម្រាប់អង្គ

សំណួរ៖ ពីខាងអនឡាញ អាចប្រើបានលេខអត្តសញ្ញាណកម្មទាំងចាស់ឬថ្មី។ ការស្នើសុំលេខអត្តសញ្ញាណត្រូវតែ ! ស្នើសុំតាមប្រព័ន្ធថ្មី។ ការប្រើប្រាស់ភាសាគឺត្រូវប្រើប្រាស់តាមប្រព័ន្ធ។

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

**ទស្សនវិស័យ:** ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងប្រជាធិបតេយ្យសម្រាប់ប្រទេសកម្ពុជា
**Vision:** Sustainable and democratic development for Cambodia

## ប្រធានបទទី៣៖ ការអនុវត្តធ្វើរបាយការណ៍ហិរញ្ញវត្ថុតាមទម្រង់របាយការណ៍ដែលបង្កើតដោយនិយ័តករសវនកម្មនិងគណនេយ្យបង្ហាញដោយ លោក លី ទុនលីម ក្រុមហ៊ុន Reach & Partner

បង្ហាញពីរបៀបនៃការបំពេញទម្រង់របាយការណ៍ដោយពន្យល់ពីការបំពេញទម្រង់យ៉ាងលម្អិតពីចំណុចនីមួយៗ។
*(ចំពោះឯកសារភ្ជាប់មិនទទួលបានពីអ្នកសម្របសម្រួលនៅឡើយទេ។)*

**<u>វគ្គសំណួរ ចម្លើយ</u>**

| សំណួរ | ចម្លើយ |
|---|---|
| ខាងអង្គការខ្ញុំ Donors នៅប្រទេសជប៉ុន ខាងខ្ញុំដឹងតែនៅពេលដែកអស់ គឺដាក់សំណើ ខ្ញុំមិនដឹងថាថវិកាទាំងនោះមកពីម្ចាស់ជំនួយណា និងចំនួនប៉ុន្មាននោះទេ។តើខ្ញុំអាចដាក់លុយដែលស្មើទាំងនោះដាក់ក្នុងIncome តែម្តងបានដែរឬទេ? | ខាងអង្គភាពដែលនៅជប៉ុននោះមិនមែនជាម្ចាស់ជំនួយនោះទេគ្រាន់តែជាការិយាល័យកណ្តាល បើដូច្នេះ យើងអាចដាក់ឈ្មោះអង្គភាពដែលបានផ្ទេរលុយមកតែម្តងទៅ។ |
| ចំណាយខាងខ្ញុំចំណាយលើការសាងសង់សាលរៀន សិក្ខាសាលា ជាដើម តើត្រូវកត់ចូលនៅខ្ទង់ចំណាយមួយណា? | ដាក់ក្នុងP11 |
| ចំពោះរបាយការណ៍ដែលមានប្រភេទរូបិយវត្ថុផ្សេងៗគ្នា ត្រូវធ្វើដូចម្តេច ? | តាមនិយ័តករគេអោយ ប្រើជាប្រាក់រៀល។ ចំពោះអត្រាប្តូរប្រាក់ខាងនិយ័តករមិនទាន់កំណត់ថាយកតាមណាអោយពិតប្រាកដបានទេ។<br><br>ចំពោះអត្រាប្តូរប្រាក់នៅមិនទាន់កំណត់ដោយនិយ័តករ ច្បាស់នៅឡើយទេ។<br><br>អត្រាប្តូរប្រាក់គេគិតតាមការិយបរិច្ឆេទជាក់ស្តែងនៃអង្គភាពនីមួយៗ។ |

| | |
|---|---|
| ការធ្វើAdjustmentពី Account Liability ឬ Withholding Tax មួយចំនួនមុនយកទិន្នន័យធ្វើរបាយការណ៍ តើជានិតិវិធីយើងធ្វើយ៉ាងណាដែរ? | ការធ្វើនិយ័តកម្ម ជាធម្មតាបើយើងចំណាយគឺយើងកត់ Debit-Expense, Credit-A/P ប្រសិនបើចំណាយនោះមិនទាន់ទូទាត់លុយក្នុងឆ្នាំហ្នឹងទេ លោកត្រូវ Reverse Expense នោះមកវិញ ដើម្បីកាត់ □/□មកវិញអោយអស់។ |
| ចំពោះអង្គភាពដែលរងសវកម្ម ត្រូវធ្វើរបាយការណ៍សវនកម្ម តែចំពោះអង្គភាពដែលមិនរងសវកម្មត្រូវធ្វើរបាយការណ៍តាមទម្រង់ដែលកំពុងតែ បង្ហាញនេះមែនទេ? | ត្រឹមត្រូវហើយ |
| ករណីអង្គការខ្ញុំជាប់លក្ខខណ្ឌតែ១ទេ គឺចំណាយលើសពី ៥០ ម៉ឺនដុល្លា តែបុគ្គលិកមិនតបតាមលក្ខណ្ឌតើយ៉ាងម៉េចវិញ? | លុះត្រាតែចូលលក្ខខណ្ឌទាំងពីរចំណុចខាងលើ បើអត់មួយក្នុងចំណោមនោះ គ្រាន់តែដាក់របាយការណ៍ធម្មតាដូចដែលកំពុងបង្ហាញនេះបានហើយ។ |
| តើ Operational Audit ឬProject Audit យកបានឬទេ? | ការហៅឈ្មោះក្រែងខុសគ្នាដូច្នេះសូមមើលទៅលើScopeនៃការធ្វើ Audit នោះវិញ។ជាឬយមអោយតែសវនកម្មដែលឆ្លុះបញ្ចាំងពីស្ថាប័នទាំងមូលគឺអាចដាក់បានហើយ។ |
| តាមការលើកឡើងរបស់លោក សេង តុលា របាយការណ៍ដែលសវនករចេញ អាចដាក់មកបានដែរ ហើយនិយ័តករក៏មានជាទម្រង់របាយការណ៍ដែលតម្រូវផងដែរ ដែលអាចដាក់ទៅនិយ័តករបាន។ សួរថា តទៅតើសវនករនឹងអាចចេញរបាយការណ៍ទម្រង់បែបនេះដែរទេ? | សវនករគាត់ចេញបាយការណ៍សវនកម្មរបស់គាត់ប៉ុណ្ណោះ តែបងឬអង្គការសមីទេជាអ្នកធ្វើរបាយការណ៍ហិរញ្ញវត្ថុ។ |
| ស្នើសុំទម្រង់របាយការណ៍នេះបានដែរទេ? | បាន នឹងជូនពេលក្រោយ ក្រោយការពិនិត្យ និងកែសម្រួលឡើងវិញហើយ។ |

## មតិបូកសរុប និងបិទកម្មវិធី ដោយលោក ឃួន ប៊ុនំសាង សមាជិកក្រុមការងារបច្ចេកទេសហិរញ្ញវត្ថុ

កិច្ចស្វាគមន៍ដល់អ្នកចូលរួម!

លោកបានធ្វើការបង្ហាញពីកាតព្វកិច្ចត្រូវអនុវត្តមួយចំនួន៖

- ដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំទៅ និយ័តករគណនេយ្យ និងសវនកម្ម នៅថ្ងៃទី ១៥ ខែ មេសា តែតាមការណែនាំយើងត្រូវបានថែម ៦០ថ្ងៃ
- ចំពោះអង្គភាពមិនរងសវនកម្ម ក៏ត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅថ្ងៃទី ១៥ ខែ មិថុនា តែប្រសិនបើអង្គភាពនោះមានរបាយការសវនកម្មរួចហើយគាត់អាចដាក់របាយការណ៍នោះតែម្តង
- ចំពោះអង្គភាពដែលរងសវនកម្មមានត្រូវដាក់របាយការណ៍នៅថ្ងៃទី១៥ ខែ កញ្ញា
- កាន់បញ្ជីរគណនេយ្យ និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យបានត្រឹមត្រូវ
- ជូនដំណឹងជាលាយលក្ខណ៍អក្សរដើម្បីជ្រើសរើសថាអង្គសមីនឹងប្រើប្រាស់ទម្រង់ណាមួយ CIFRS ឬ CIFRS for SME
- ស្នើសុំការអនុញ្ញាតលើការកំណត់ថ្ងៃបិទបញ្ជីគណនេយ្យប្រសិនបើខុសពី ៣១ ធ្នូ
- លិខិតស្នើសុំត្រូវដាក់មុនថ្ងៃទី ៣០ មិថុនា ២០២២ ឬ ៣ ខែសម្រាប់អង្គភាពថ្មី
- ការប្រើប្រាស់ភាសា៖ ត្រូវជូនដំណឹងដែរនៅថ្ងៃទី ៣០ ខែ មេសា (គសក នឹងរកទម្រង់លិខិតនោះជូនអង្គការសមាជិកពេលក្រោយ)
- ប្រើប្រាស់ប្រព័ន្ធអនឡាញ (E-Filing System)
- ស្នើសុំការអនុញ្ញាតលើការប្រើប្រាស់រូបិយប័ណ្ណក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ
- ត្រូវអានមានដូចជា ប្រកាស០០១ ចុះ ១២ មករា ២០២២ អនុក្រិត្យ៧៩ ចុះ០១ មិថុនា ២០២០ និងសេចក្តីណែនាំ
- បទបង្ហាញការអនុវត្ត និងប្រើប្រាស់ទម្រង់
- ការអនុវត្តធ្វើរបាយការណ៍ហិរញ្ញវត្ថុតាមទម្រង់របាយការណ៍ដោយក្រុមហ៊ុន Reach & Partners។
- អនុសាសន៍
- ចុះបញ្ជីជាមួយ នគស (បើមិនទាន់ចុះ)
- ចូលក្នុងប្រព័ន្ធសាកល្បងបើបានចុះបញ្ជីហើយ
- អនុវត្តលើទម្រង់អោយបានញឹកញាប់
- រៀបចំលិខិតស្នើសុំ ឬជូនដំណឹងតាមការកំណត់
- តាមដានការវិវត្តប្រព័ន្ធ E-Filing របស់ នគស

សូមថ្លែងអណរគុណដល់ នគស ក្រុមហ៊ុនReach & Partners និងអង្គការ CCC ព្រមទាំងម្ចាស់ជំនួយរបស់ CCC ផងដែរដែលបានផ្តល់ថវិកាគាំទ្រនូវកម្មវិធីនេះ សូមប្រសិទ្ធពរជ័យ សិរីបវរមហាប្រសើរ ដល់ក្រុមការងារនិងអ្នក

ចូលរួមទាំងអស់គ្នាជួបតែសេចក្តីសុខ សេចក្តីចម្រើនជាពិសេសក្នុងឱកាសឆ្នាំថ្មីនេះ។ សូមប្រកាសបិទកម្មវិធីចាប់ពីពេលនេះតទៅ សូមអរគុណ!

## ៣) លទ្ធផលនៃការវាយតម្លៃនៃវេទិការៀនសូត្រ

បន្ទាប់ពីបញ្ចប់វេទិកាសិក្សារៀនសូត្រស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុលើកទី២៩ កញ្ញាថន សុខុមាលាបានស្នើឲ្យសិក្ខាកាមដែលបានចូលរួមបំពេញទម្រង់វាយតំលៃទៅលើវេទិកាសិក្សារៀនសូត្រទាំងមូលតាមរយៈប្រព័ន្ធអនឡាញ (Google Form)។ ខាងក្រោមគឺជាលទ្ធផលលម្អិតនៃការវាយតម្លៃរបស់សិក្ខាកាមទាំងមូលចំនួន ២៥នាក់ ក្នុងចំណោមសិក្ខាកាមតាមអនឡាញសរុប ១៧៥នាក់ និងមកផ្ទាល់៥១នាក់។

### ៣.១) ចំណុចទូទៅនៃវេទិកាសិក្សារៀនសូត្រ

ចំពោះការដាក់ពិន្ទុគឺធ្វើឡើងពីលេខ ១ (អន់បំផុត) ដល់លេខ៥ (ល្អបំផុត)ដើម្បីស្វែងយល់ពីការពេញចិត្តរបស់អ្នកចូលរួមក្នុងវេទិការៀនសូត្រនេះ។ ក្រាបខាងក្រោមបង្ហាញថា សិក្ខាកាមភាគច្រើនបានពេញចិត្តចំពោះប្រធាននៃវេទិការៀនសូត្រដែលបានផ្តល់ជូនដោយអង្គការគសក ព្រមទាំងការពេញចិត្តចំពោះបទបង្ហាញដែលវាគ្មិនបានបកស្រាយ។ ជាលទ្ធផលយើងឃើញថា ក្នុងចំណោមអ្នកផ្តល់មតិត្រឡប់ចំនួន២៥រូប គឺមាន៤រូបដាក់លេខ៣ (មធ្យម) ចំនួន១៦រូបដាក់លេខ៤(ល្អ) និងលេខ៥ ចំនួន៥រូប (ល្អប្រសើរ)។




### ៣.២) ចំណុចសិក្ខាកាមរៀនសូត្របានច្រើនជាងគេ




តាមលទ្ធផលខាងក្រោម បង្ហាញថា មានបីចំណុចដែលសិក្ខាកាមរៀនសូត្របានច្រើនជាងគេ។ លើសពីនេះទៀត ចំណុចដែលលេចធ្លោជាងគេមានគឺ លក្ខខណ្ឌតម្រូវក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញ (E-Filling system) របស់ ន គ ស ក្នុងការដាក់បញ្ជូនរបាយការណ៍នានា ដែលមានភាគរយខ្ពស់ជាងគេដល់៥២%។ ចំណុចបន្ទាប់គឺជានីតិវិធីក្នុងការបញ្ចូលទិន្នន័យនៃរបាយការណ៍ហិរញ្ញវត្ថុនិងការបំពេញទៅតាមទម្រង់របស់និយ័តករគណនេយ្យ និងសវនកម្ម ដែលមាន៤០%។ ដោយឡែក៨%(ស្មើនឹង២នាក់) គឺពុំបានផ្តល់យោបល់។

### ៣.៣) ចំណុចសិក្ខាកាមនៅតែត្រូវការពន្យល់បន្ថែមពីវេទិកាលើកនេះ

តាមលទ្ធផលបង្ហាញថា សិក្ខាកាមត្រូវការពន្យល់បន្ថែមលើចំណុចចំនួនពីរចំណុចសំខាន់ៗ ពីវេទិកានេះមានដូចជា ១.ពន្យល់បន្ថែមលើរបៀបនៃការបំពេញទម្រង់របាយការណ៍ប្រចាំឆ្នាំដែលត្រូវដាក់ជូនទៅ នគស តាមរយៈE-Filing System ២. ភាពខុសប្លែកគ្នានៃ currency translation, Note4, and Note 9 ។

## របៀបវារៈនៃវេទិកា

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០ -០៨:៣០ | ការចុះឈ្មោះអ្នកចូលរួម | ក្រុមការងារ គក.ស. |
| ០៨:៣០-០៨:៤០ | - ការណែនាំពី បទបញ្ជាផ្ទៃក្នុងសម្រាប់វេទិកាវៀនសូត្រ<br>- គោរពភ្លេងជាតិ<br>- ប្រកាសគោលបំណងវេទិកាវៀនសូត្រ | **អ្នករៀបចំកម្មវិធី**<br><br>អង្គការ គក.ស. |
| ០៨:៤០-៩:១៥ | មតិស្វាគមន៍ ដោយ**លោកស្រី ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិអង្គការ | |

| | | |
|---|---|---|
| | គ.ក.ស.<br><br>សុន្ទរកថាបើកកម្មវិធីដោយ**លោក សេង តុលា** អគ្គនាយករងនៃនិយ័តករគណនេយ្យ និងសវនកម្ម (ស.គ.ន) | |
| ០៩:១៥ -០៩:៣០ | សម្រាកអាហារសម្រន់ | |
| ៩:៣០ -១១:០០ | **ប្រធានបទទី១៖ ការធ្វើបទបង្ហាញ និងការពន្យល់បន្ថែមលើសេចក្តីណែនាំស្តីពី ការអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្មសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ**<br><br>**វេទិកាសំណួរ និងចម្លើយ** | **លោក សឿន បូតេ អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព**<br><br>(ធ្វើបទបង្ហាញតាម Online) |
| ១១:០០-១២:០០ | **ប្រធានបទទី២៖ ការធ្វើបទបង្ហាញទូទៅអំពីទម្រង់របាយការណ៍ដាក់ជូននិយ័តករគណនេយ្យ និងសវនកម្ម។**<br>• របៀបចូលទៅកាន់ទម្រង់របាយការណ៍<br>• ការបង្ហាញព័ត៌មានជាទូទៅនៅក្នុងទម្រង់របាយការណ៍ | **លោក រឿន ប៊ុនហេង តំណាងក្រុមហ៊ុនReach and Partner Co.,Ltd និងជាសមាជិកនៃក្រុមការងារចម្រុះពន្ធដារនៃអង្គការសង្គមស៊ីវិល** |
| ១២:០០-១៣:៣០ | ពិសារអាហារថ្ងៃត្រង់រួមគ្នា | |
| ១៣:៣០-៤:១៥ | **ប្រធានបទទី៣៖** ការអនុវត្តធ្វើរបាយការណ៍ហិរញ្ញវត្ថុតាមទម្រង់របាយការណ៍ដែលបង្កើតដោយនិយ័តករសវនកម្ម និងគណនេយ្យ | **លោក លី វុធធីម និង លោក ចាន់ សាវ៉ាន់ តំណាងក្រុមហ៊ុនReach and Partner Co.,Ltd** |
| ៤:១៥-៤:៣០ | **សរុបខ្លឹមសារ និងបិទកម្មវិធី** | **លោក យួន ប៊ុនសាង តំណាងក្រុមការងារគ្រប់គ្រងហិរញ្ញវត្ថុ និងជា** |

| | | |
|---|---|---|
| | | អ្នកគ្រប់គ្រងហិរញ្ញវត្ថុ<br>អង្គការ ហេឡិនខេល័រ |